ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តស្វាយរៀង
លេខ:០៣៣ ដ.ក

ក្រសួងមុខងារសាធារណៈ រដ្ឋបាល
ចូល
លេខ: ៥២៩៥
មកដល់ថ្ងៃទី ...
ម៉ោង ១០...២០

# ដីកា
## ស្តីពី
## ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ខេត្តស្វាយរៀង ដើម្បីជំរុញការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិ កំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០១៥ - ២០១៨

## អភិបាល នៃគណៈអភិបាលខេត្តស្វាយរៀង

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៦/៣១៧ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលខេត្តស្វាយរៀង
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក
- អនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- យោងលិខិតលេខ ១៨៤៦ មស.គករ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ ស្តីពីការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០១៥ - ២០១៨
- យោងតាមការចាំបាច់របស់រដ្ឋបាលខេត្ត

## សម្រេច

**ប្រការ១.**_

ត្រូវបានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ របស់រដ្ឋបាលខេត្តស្វាយរៀង ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១.ឯកឧត្តម **ហ៊ី ទតនៈ** អភិបាលរងខេត្ត | ប្រធាន |
| ២.លោក **គង់ ចាន់ថន** ប្រធានមន្ទីរមុខងារសាធារណៈខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៣.លោក **រស់ ផារិទ្ធ** នាយករដ្ឋបាលសាលាខេត្ត | សមាជិក |

៤.លោក ជូ សុធី ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត សមាជិក

៥.លោក គៀត សៀមហេង ប្រធានរតនាគារខេត្ត សមាជិក

៦.លោក អភិបាលក្រុង ស្រុក ទាំង៨ សមាជិក

៧.លោក ពុត សុផល អនុប្រធានមន្ទីរមុខងារសាធារណៈខេត្ត មន្ត្រីបង្គោល

៨.លោក គង្គ សុភមង្គល ប្រធានការិយាល័យ នៃមន្ទីរមុខងារសាធារណៈខេត្ត មន្ត្រីបង្គោល

**ប្រការ២._**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខប្រធានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ខេត្ត ក្នុងការគ្រប់គ្រង និងដឹកនាំគ្រប់ការងារពាក់ព័ន្ធទៅនឹងកម្មវិធីយុទ្ធសាស្ត្រ និងសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់ខេត្ត
- សម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈរវាងក្រសួងស្ថាប័នសាមីថ្នាក់ជាតិ និងថ្នាក់ខេត្ត ជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ និងសកម្មភាពការងារកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- តាមដានត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងធ្វើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈជូនប្រធានស្ថាប័នសាមីជាប្រចាំ
- ត្រូវវាយការណ៍អំពីវឌ្ឍនភាពឲ្យបានទៀងទាត់រៀងរាល់ត្រីមាស ទៅលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- ក្រុមការងារត្រូវផ្តល់កិច្ចសហការ និងសម្របសម្រួលជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ តាមរយៈមន្ត្រីបង្គោលក្នុងការស្វែងរក និងប្រមូលព័ត៌មាន ការរៀបចំផែនការសកម្មភាពតាមដានត្រួតពិនិត្យ និងវាយតម្លៃការរៀបចំរបាយការណ៍ និងបញ្ជូនរបាយការណ៍សង្ខេបនូវសូចនាករដែលទាក់ទងនឹងវឌ្ឍនភាព នៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ របស់សាមីក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ខេត្ត មកលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ឬនាយកដ្ឋានជំនាញនៃក្រសួងមុខងារសាធារណៈ ។

**ប្រការ៣._**

នាយករដ្ឋបាលសាលាខេត្ត ប្រធានមន្ទីរ-អង្គភាពជុំវិញខេត្ត លោកអភិបាលក្រុង-ស្រុក និងឯកឧត្តមអស់លោក ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវអនុវត្តតាមដីកានេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/៙

ស្វាយរៀង ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦

អភិបាលខេត្ត

ម៉ែន_វិបុល

<u>កន្លែងទទួល៖</u>

- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ